# ការគាំពារសម្រាប់គ្រួសារមានកូនតូច រដ្ឋ Maine

## ប្រព័ន្ធចាត់បញ្ជូន CradleME

ឬហៅទូរស័ព្ទមកលេខ
**1-888-644-1130**

CradleME ជួយភ្ជាប់អ្នកជាមួយនឹងសិទ្ធិទទួលបានសេវាតាមផ្ទះ
សម្រាប់អ្នក និងកូនរបស់អ្នកដោយឥតគិតថ្លៃ ។ CradleME
គឺជាគម្រោងជាដៃគូ រវាងកម្មវិធីជាច្រើន ។

## WIC Nutrition Program (កម្មវិធីអាហាររូបត្ថម្ភ WIC)

ឬហៅទូរស័ព្ទមកលេខ
**207-287-3991**

WIC បម្រើសេវាដល់ស្ត្រីមានផ្ទៃពោះ ស្ត្រីបំបៅដោះកូន
និងកុមារអាយុរហូតដល់ 5 ឆ្នាំ ដោយបូករួមទាំងក្មេងដែលគេទទួល
ចិញ្ចឹមផងដែរ ។ WIC គឺជាអ្នកផ្តល់អាហាររូបត្ថម្ភដ៏ពេញលេញ និងផ្តល់
ជូនអាហារសុខភាព ការអប់រំអំពីអាហាររូបត្ថម្ភ ជំនួយគាំទ្រផ្នែក
បំបៅកូនដោយទឹកដោះម្តាយ និងការចាត់បញ្ជូនអតិថិជន
ទៅកាន់អ្នកផ្តល់សេវាផ្សេងទៀត ។

## ការថែទាំសុខភាពសាធារណៈ

ឬហៅទូរស័ព្ទមកលេខ
**1-888-644-1130**

ផ្នែកថាំទាំសុខភាពសាធារណៈប្រចាំមជ្ឈមណ្ឌលគ្រប់គ្រងជំងឺរដ្ឋមេន
មានបម្រើសេវាកម្មថែទាំសុខភាពតាមផ្ទះដល់គ្រួសាររបស់រដ្ឋមេន ។
គិលានុបដ្ឋាកសុខភាពសាធារណៈ អាចចុះជួយស្ត្រីមានផ្ទៃពោះ
និងស្ត្រីដែលទើបសម្រាលកូនរួច និងទារកទើបកើត
ព្រមទាំងទារកដែលមានអាយុរហូតដល់ 12 ខែ ។ បើអ្នកមានសំណួរអំពី
សុខភាព ឬអំពីសុខភាពទារករបស់អ្នក សូមស្នើសុំជួបគិលានុបដ្ឋាក
បានគ្រប់ពេល ដោយការហៅទូរស័ព្ទមកកាន់លេខរបស់ ក្រុម CradleME ។

## Maine Mom

ឬហៅទូរស័ព្ទមកលេខ
**1-888-644-1130**

MaineMOM
ធ្វើអោយប្រសើរឡើងនូវការថែទាំសម្រាប់អ្នកមានផ្ទៃពោះ
និងស្ត្រីក្រោយសម្រាល ដែលញៀនអាភៀន និងទារករបស់ពួកគេ
ដោយរួមបញ្ចូលសេវាគាំពាមាតា និងទារក និងព្យាបាលការញៀនថ្នាំ
។ ព័ត៌មានអំពីទីតាំងសេវារបស់ MaineMOM និងរបៀបបញ្ជូន
អតិថិជនទៅរកសេវា មាននៅឯ MaineMOM.org ។

## Child Care និង Head Start

ការជ្រើសរើសការថែទាំកុមារ
នឹងក្លាយជាការសម្រេចចិត្តដ៏សំខាន់បំផុតមួយរបស់អ្នក
។ កម្មវិធីគុណភាពផ្តល់ការថែទាំ
និងគាំទ្រដល់ការរៀនសូត្ររបស់កុមារតូច ហើយ Maine
មានធនធានដើម្បីជួយ!

Child Care Affordability Program (កម្មវិធីថែទាំកុមារក្នុង
តម្លៃទាប)
ជួយចេញថ្លៃសេវាថែទាំដល់គ្រួសារកុមារណាដែលមានសិទ្ធិ
ទទួលបានសេវានេះ ដើម្បីឲ្យឪពុកម្តាយ អាចធ្វើការ
ទៅសាលារៀន ឬចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលការងារ
។ ជំនួយក៏មានផ្តល់ជូនដែរ
សម្រាប់គ្រួសារដែលមានសិទ្ធិទទួលបានជំនួយនេះ
ដែលមានមនុស្សចាស់ ចូលនិវត្តន៍
ជាអាណាព្យាបាលស្របច្បាប់របស់កុមារ ។

កម្មវិធី Head Start
ផ្តល់ជូនសេវាអប់រំដែលមានគុណភាពខ្ពស់ ដល់កុមារតូច
ដោយឥតគិតថ្លៃ និងអាហារូបត្ថម្ភដ៏ទូលំទូលាយ
សុខភាព សុខភាពផ្លូវចិត្ត ការអប់រំមាតាបិតា/អ្នកថែទាំ
និងជំនួយមុនពេលសម្រាល ដល់ស្ត្រីដែលមានសិទ្ធិ
ទទួលបានសេវានេះ និងគ្រួសារដែលមានកូនចាប់ពីកើត
រហូតដល់អាយុ 5 ឆ្នាំ ។

## MaineCare

ហៅទូរស័ព្ទមកកាន់
**1-855-797-4357**

MaineCare គឺជាកម្មវិធី Medicaid របស់រដ្ឋ Maine
ដែលផ្តល់ការសេវាធានារ៉ាប់រងសុខភាពដោយឥតគិតថ្លៃ
ឬតម្លៃទាបដល់មនុស្សធំដែលមានប្រាក់ចំណូលទាប កុមារ
ស្ត្រីមានផ្ទៃពោះ មនុស្សចាស់ និងជនដែលមានពិការភាពជាប់ខ្លួន ។
MaineCare ជួយអ្នក ឲ្យទទួលបានការថែទាំសុខភាព តាមតម្រូវការ
របស់អ្នក ដើម្បីថែរក្សាខ្លួនអ្នក ឬគ្រួសាររបស់អ្នក ។
អ្នកអាចស្វែងរកព័ត៌មានបន្ថែម និងដាក់ពាក្យស្នើសុំជំនួយ
MaineCare ដោយចូលទៅកាន់ MyMaineConnection.gov ។

## CoverME

ឬហៅទូរស័ព្ទមកលេខ
**207-642-7991**

កម្មវិធីធានារ៉ាប់រងសុខភាពរដ្ឋមេន (Health Coverage for Maine)
(CoverME.gov) មានផ្តល់ជូនព័ត៌មានអំពីការធានារ៉ាប់រងសុខភាព
ដោយឥតគិតថ្លៃ និងតម្លៃថោក ដែលជាជម្រើសសម្រាប់គ្រួសារ
រដ្ឋមេន ។ អ្នកក៏អាចស្វែងរកកម្រងព័ត៌មានអំពី
អង្គការប្រចាំមូលដ្ឋាន ដែលអាចជួយអ្នកឲ្យយល់បាននូវជម្រើសការ
ធានារ៉ាប់រងសុខភាពរបស់អ្នក និងការបំពេញពាក្យសុំទិញធានារ៉ាប់
រងសុខភាព ។

## Help Me Grow Maine

ឬហៅទូរស័ព្ទមកលេខ
**1-833-714-7969**

Help Me Grow Maine គឺជាចំណុចកណ្តាលនៃការផ្តល់ជំនួយ
ដែលត្រូវបានរៀបចំឡើងដើម្បីភ្ជាប់គ្រួសាររបស់កុមារ ពីពេលកើត
រហូតដល់អាយុប្រាំបីឆ្នាំ ក៏ដូចជាអ្នកផ្តល់ការថែទាំដល់ស្ត្រីមានផ្ទៃពោះ
ឲ្យទទួលបានព័ត៌មាន និងសេវា អំពីការលូតលាស់សតិបញ្ញាកុមារ
ក៏ដូចជាធនធានសហគមន៍ផងដែរ ។ ក្នុងភាពជាដៃគូជាមួយ 211
Maine អ្នកផ្តល់ការថែទាំ និងអ្នកផ្តល់សេវា អាចទាក់ទង Help Me
Grow សម្រាប់ជំនួយបន្ថែម ។ Help Me Grow នឹងស្តាប់
ភ្ជាប់គ្រួសារជាមួយនឹងសេវា ព្រមទាំងជួយតាមដាន ចំពោះអ្នកផ្តល់
ការថែទាំ និងធនធានសម្រាប់ចាត់បញ្ជូនអតិថិជន ។

## Maine Families

គ្រួសាររដ្ឋមេន (Maine Families) គឺជាបណ្តាញទូទាំងរដ្ឋ នៃក្រុម
សហគមន៍ដែលបម្រើសេវាកម្មចំពោះស្ត្រីមានផ្ទៃពោះ
និងឪពុកម្តាយដែលមានទារកទើបកើត ។ ក្រុមអ្នកមើលថែ និងអ្នក
ចុះជួយតាមផ្ទះដែលមានវិជ្ជាជីវៈ នឹងចាប់ដៃគូជាមួយនឹងអ្នក ដើម្បីអាច
ទទួលបានព័ត៌មាន និងធនធាននានា ដែលអាចជួយជ្រោម
ជ្រែងសុខភាពផ្លូវកាយ និងសុខភាពផ្លូវចិត្តនៃកូនតូចរបស់អ្នក
និងគ្រួសារអ្នកទាំងមូល ។

## អន្តរាគមន៍ដំបូងសម្រាប់ ME, កុមារអាយុពី 0-3 ឆ្នាំ និងការអប់រំសាធារណ:សមរម្យដោយឥតគិតថ្លៃ, កុមារអាយុពី 3-5 ឆ្នាំ

ឬហៅទូរស័ព្ទមកលេខ
**877-770-8883**

ផ្តល់សេវាដោយឥតគិតថ្លៃ និងស្ម័គ្រចិត្ត ចាប់ផ្តើមពីពេលកើត
នាយកដ្ឋានអប់រំរបស់រដ្ឋ Maine មានផ្តល់ជូនកម្មវិធីសេវា ការលូតលាស់របស់
កុមារប្រកបដោយសុខភាពល្អ និងកម្មវិធីសិក្សា ។ អន្តរាគមន៍ដំបូងសម្រាប់
ME ពីពេលកុមារកើត រហូតដល់អាយុបីឆ្នាំ ផ្តល់សេវាផ្តោតលើលក្ខណ:គ្រួសារ
របស់កុមារ ការវាយតម្លៃលើការអភិវឌ្ឍន៍សតិបញ្ញា ជាលក្ខណ:បុគ្គល
ការគាំពារការសិក្សា និងធនធានផ្សេងទៀត ។ កុមារតូច អាយុពី 3 ទៅ 5 ឆ្នាំ
ទទួលបានអត្ថប្រយោជន៍ពីការអប់រំសាធារណ:សមរម្យដោយឥតគិតថ្លៃ
និងសេវាអភិវឌ្ឍន៍សតិបញ្ញា ដែលពាក់ព័ន្ធ (សេវាការអភិវឌ្ឍន៍សតិបញ្ញាកុមារ
ផ្នែកខ) ។

## ផែនការថែទាំសុខភាពដោយសុវត្ថិភាព (POSC)

ផែនការរបស់រដ្ឋមេន អំពី Safe Care (ការថែទាំកុមារប្រកបដោយសុវត្ថិភាព)
ត្រូវបានបង្កើតឡើងរវាងអ្នកផ្តល់សេវាកម្មការថែទាំសុខភាព ឬអ្នកផ្តល់សេវា
សង្គមកិច្ច, ម្តាយ និង/ឬអ្នកមើលថែក្មេងផ្សេងទៀត ដើម្បីកំណត់រកភាពខ្លាំង
និងតម្រូវការរបស់គ្រួសារ ធនធានដែលមានប្រយោជន៍ និងសកម្មភាព
ដើម្បីអាចផ្តល់ភាពជ្រោមជ្រែងបានប្រសើរបំផុតដល់ទារក និងគ្រួសារ
របស់ពួកគេដែលកំពុងប្រឈមនឹងថ្នាំញៀន ។ ផែនការនៃការថែទាំ
សុខភាពប្រកបដោយសុវត្ថិភាព ជាធម្មតា មានរួមបញ្ចូលនូវ
សេវាកម្មចាត់បញ្ជូនទៅសេវាកម្មនានា ឬផ្តល់ជូនព័ត៌មានទំនាក់ទំនង
ដល់គ្រួសារ ដើម្បីយកទៅប្រើប្រាស់នៅពេលក្រោយ ។

## Children and Youth with Special Healthcare Needs (កម្មវិធីកុមារ និងយុវជនដែលមានតម្រូវការពិសេសផ្នែកថែទាំសុខភាព)

ឬហៅទូរស័ព្ទមកលេខ
**1-800-698-3624**

Children and Youth with Special Health Care Needs ធ្វើការជាមួយគ្រួសារ
ដែលមានកូនតូច និងយុវជន ដែលមានតម្រូវការពិសេសផ្នែកថែទាំសុខភាព
ដែលមានអាយុក្រោម 22 ឆ្នាំ ។ CSHN អាចជួយដឹកនាំ គ្រួសារ
និងអង្គការនានា ក្នុងការស្វែងរកធនធានដែលអាចផ្តល់
ជំនួយបានប្រសើរបំផុតចំពោះតម្រូវការរបស់កូនៗទាំងអស់ ។ បុគ្គលិក
របស់អង្គការ អាចណែនាំដល់គ្រួសារទាំងនោះ តាមរយ:ប្រព័ន្ធវេជ្ជសាស្ត្រ
ដែលមានភាពស្មុគស្មាញ ភ្ជាប់ទំនាក់ទំនងរបស់ពួកគេទៅកាន់សេវាកម្មថែទាំ
សុខភាព ដែលអាចធ្វើឲ្យការថែទាំព្យាបាល បានផលប្រសើរបំផុតចំពោះអ្នក
ជំងឺ ។

## Early Childhood Consultation Partnership (ដៃគូពិគ្រោះយោបល់កុមារតូច)

ឬហៅទូរស័ព្ទមកលេខ
**207-624-7991**

អ្នកប្រឹក្សាយោបល់របស់ ECCP ធ្វើការជាមួយគ្រួសារ
អ្នកផ្តល់សេវាថែទាំកុមារ និងគ្រូបង្រៀន
ដើម្បីគាំទ្រដល់តម្រូវការសុខភាពផ្លូវចិត្តរបស់កុមារដែលមានអាយុពី
0-8 ឆ្នាំ ដែលមានបញ្ហាអាកប្បកិរិយា ឬអារម្មណ៍
នៅឯកន្លែងថែទាំកុមារ ឬសាលារៀនរបស់ពួកគេ ។
សេវាដែលផ្តល់ជូនដោយ ECCP មានរយ:ពេលខ្លី ផ្តល់ជូនដោយ
ស្ម័គ្រចិត្ត និងឥតគិតថ្លៃ ។

ដើម្បីស្កេនកូដ QR សូមបើកកាមេរ៉ា
នៅលើឧបករណ៍របស់អ្នក
ហើយតម្រង់វាទៅលេខកូដដែលអ្នកចង់ស្កេន ។
តំណមួយនឹងលេចឡើងនៅលើអេក្រង់របស់អ្នក —
ចុចវាដើម្បីចូលទៅក្នុងគេហទំព័រ នោះ ។

អង្គភាពនេះផ្តល់ឱកាសស្មើភាពដល់មនុស្សគ្រប់រូប ។